# អត្ថរថាប្រភពនៃកំណើតសេដ្ឋកិច្ច

## ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៩

បណ្ឌិត ស៊ិន ម៉េង ស្រ៊ុន
ប្រធានអនុក្រុមសិក្សាស្រាវជ្រាវសេដ្ឋកិច្ចកសិកម្ម

នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC)

ទីស្តីការគណៈរដ្ឋមន្ត្រី

# អត្ថបទស្រាវជ្រាវប្រភពនៃកំណើនសេដ្ឋកិច្ច

ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៩

## ១.សេចក្តីផ្តើម

មិនថាក្នុងកាលៈទេសៈណានោះទេ អង្ករតែងតែជាអាហារដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។ ក្នុងមួយឆ្នាំៗប្រជាជនកម្ពុជាម្នាក់ទទួលទានអង្ករអស់ប្រមាណ ១៤៣ គីឡូក្រាម។ គ្រួសារចំនួន៦៧% ចូលរួមនៅក្នុងការងារផលិតកម្មអង្ករ។ សម្រាប់គ្រួសារ អង្ករត្រូវបានចាត់ទុកថាជាប្រភេទដំណាំដែលផ្តល់នូវប្រាក់ចំណូល និងរក្សាសន្តិសុខស្បៀង។ សម្រាប់ប្រទេសជាតិវិញ កសិកម្មនៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចអភិវឌ្ឍជាតិ។ វិស័យកសិកម្មរួមចំណែកប្រមាណ ៣៤,៤% នៅក្នុងផលិតផលក្នុងស្រុក ( GDP) ឆ្នាំ២០០៨ ដែលក្នុងនោះ៩%បានមកពីដំណាំស្រូវ។ នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ជ្រុងយុទ្ធសាស្ត្រមួយ គឺការជំរុញដល់ "ការលើកស្ទួយវិស័យកសកម្ម" សំដៅឲ្យមានសន្តិសុខស្បៀង បង្កើនប្រាក់ចំណូល ការងារ និងលើកកំពស់ ស្ថានភាពអាហារូបត្ថម្ភសម្រាប់ប្រជាជនគ្រប់រូប តាមរយៈការលើកកំពស់ផលិតភាព ពិពិធកម្ម និងពាណិជ្ជភាវូបនីយកម្មវិស័យ កសិកម្មដោយមានការការពារចំពោះបរិស្ថាន និងសន្តិសុខស្បៀង។

## ២. ស្ថានភាពដំណាំស្រូវកន្លងមក រហូតដល់បច្ចុប្បន្ន

### ១.ថវិកាចំណាយបច្ចុប្បន្នរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ថវិកាចំណាយលើវិស័យកសិកម្ម ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៦ នៅតែស្ថិតក្រោម២.៥ ភាគរយនៃការចំណាយលើវិស័យកសិកម្ម មានការធ្លាក់ចុះមកនៅតិចជាង២.0ភាគរយ បើទោះជាមានការកើនឡើងបន្តិចបន្តួចនៃតួលេខទឹកប្រាក់នេះក៏ដោយ។

**តារាង១: ថវិកាចំណាយសរុបបច្ចុប្បន្នរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ឆ្នាំ២០០២ ដល់ឆ្នាំ២០១០ (គម្រោង)**

| ចំនួន | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ បច្ចុប្បន្ន | ២០១០ គម្រោង |
|---|---|---|---|---|---|---|---|---|---|
| ចំណាយបច្ចុប្បន្នរបស់ MAFF (លានរៀល) | ៣៩.៦៥២ | ៣៩.០២៤ | ៣៨.៥៥២ | ៤៧.០៩៩ | ៥៥.៩៩១ | ៥៧.៦៥៥ | ៦៣.១៧៩ | ៧៦.៩៨៧ | ៨៧.៥០៩ |
| ជាលានដុល្លារអាមេរិច | ១០.១ | ៩.៨ | ៩.៦ | ១១.៦ | ១៣.៦ | ១៤.២ | ១៥.៦ | ១៨.៥ | ២០.៨ |
| %នៃថវិកាចំណាយសរុបបច្ចុប្បន្ន | ២,៥% | ២.២% | ២,២% | ២,៤% | ២,៤% | ១,៧% | ១,៧% | ១,៨% | ២,០% |
| សរុប ( លានរៀល) | ១.៥៧៤.១១៣ | ១.៧៥៨.១៩៤ | ១.៧៩៥.៦៥២ | ១.៩៦៧.០ ៥៥ | ២.៣៥៤.៥ ៣៧ | ៣.៣២២.៧៨ ៦ | ៣.៦៣៥.៨៣ ២ | ៤.៣៥៩.០៦ ៧ | ៤.៣៣៩.២៩ |
| អត្រាប្តូរប្រាក់(រៀល/ដុល្លារ | | | | | | | | | |

ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០០៩

## ២. ទិន្នផលអង្ករ

ក្នុងឆ្នាំ១៩៩៥ ទិន្នផលស្រូវរបស់ប្រទេសកម្ពុជាបានសម្រេចដល់កម្រិតអាចផ្គត់ផ្គង់ខ្លួនឯងបាន គឺកើនឡើងពី ២លានតោន ក្នុងទសវត្សឆ្នាំ១៩៨០ ដល់ ៣,៥ លានតោន ដោយសារមានការពង្រីកតំបន់ដាំដុះ និងការកែលម្អផលិតភាព ( តារាង២)។ ពីឆ្នាំ២០០៤ ដល់ ២០០៨ កំណើនជាមធ្យមក្នុងតំបន់ដាំដុះគឺ ២,៤៤ ភាគរយ ដែលមានកម្រិតលំអៀង ពី ១,១៦% ទៅ ៤,០៩% អាស្រ័យទៅតាមអាកាសធាតុ និង កត្តាមិនល្អផ្សេងទៀត ដូចជាជំងឺ និងការបំផ្លាញពីសត្វល្អិត។

ក្នុងផ្ទៃដីមួយ ទិន្នផលស្រូវបានកើនឡើងជាលំដាប់ពី១,៩៨តោន/ហិចតា ក្នុងឆ្នាំ២០០៤ ដល់ ២,៧៥តោន/ហិចតា ក្នុងឆ្នាំ២០០៨ ដោយគិតជាមធ្យមទទួលបាន ២,៤៦តោន/ហិចតា។ ទិន្នផលស្រូវវស្សាមានចំនួន៨០%នៃចំនួនទិន្នផលសរុប ធៀបទៅនឹងស្រូវប្រាំង។ ស្រូវប្រាំងដែលពឹងផ្អែកទៅលើការស្រោចស្រពទឹកផ្ដល់ទិន្នផលប្រមាណ ៤,០តោន/ហិចតា ធៀបទៅនឹងស្រូវវស្សា ដែលផ្ដល់ទិន្នផលជាមធ្យម ២,៤ តោន/ហិចតា អាស្រ័យទៅតាមភាពអនុគ្រោះនៃធម្មជាតិ។

**តារាង២: ស្ថិតិស្ដីពីទិន្នផលអង្ករ ឆ្នាំ ២០០៤-២០០៨**

| ខ្ទង់ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ (លានហិចតា) | ២,៣៨ | ២,៤៤ | ២,៥៤ | ២.៥៩ | ២.៦២ |
| ផ្ទៃដីប្រមូលផល (លានហិចតា) | ២,១១ | ២,៤១ | ២,៥២ | ២.៥៧ | ២,៦១ |
| ផលិតភាព (តោន/ហិចតា) | ១,៩៨ | ២,៤៨ | ២,៤៨ | ២,៦២ | ២,៧៥ |
| ទិន្នផលសរុប (លានតោន) | ៤,១២ | ៥,៩៤ | ៦,២៦ | ៦,៧៣ | ៧,១៨ |
| ទិន្នផលអង្ករលើសតម្រូវការ(លានតោន) | ០,៤២ | ១,៣២ | ១,៤៣ | ១,៦៥ | ២,០៣ |
| *ទិន្នផលស្រូវលើសតម្រូវការ (លានតោន) | ០,៦៥ | ២,០៦ | ២,២៤ | ២,៥៦ | ៣,១៦ |

ប្រភព: ដកស្រង់ពីរបាយការណ៍ប្រចាំឆ្នាំ ២០០៨-២០៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកតាបំលែងពីស្រូវទៅជាអង្ករ= ០,៦៤។

## ៣. ធារាសាស្ត្រ

ក្នុងឆ្នាំ ២០០១ មានផ្ទៃដីស្រែចំនួនប្រហែលជា១០%ប៉ុណ្ណោះដែលមានប្រព័ន្ធធារាសាស្ត្រស្រោចស្រព។ ក្នុងឆ្នាំ ២០០៦ ផ្ទៃដីដែលមានប្រព័ន្ធធារាសាស្ត្រស្រោចស្រព តាមការប៉ាន់ប្រមាណមានតិចជាង ២០%បន្តិចនៃផ្ទៃដីកសិកម្ម (ប្រហែល ៣០០.០០០ ហិចតា) ដែលនេះជាការបង្ហាញឲ្យឃើញអំពីការរីកចម្រើនគួរសម។ ប្រព័ន្ធធារាសាស្ត្រកំពុងបន្តពង្រីកដោយរាជរដ្ឋាភិបាលកម្ពុជា ទោះបីជាត្រូវចំនាយថវិកាច្រើនក៏ដោយ។ មានការប៉ាន់ប្រមាណថា នៅត្រឹមឆ្នាំ២០១០ នឹងមានដីស្រែចំនួន២៥%ដែលមានប្រព័ន្ធធារាសាស្ត្រស្រោចស្រព។ ច្បាប់ស្ដីពីការបង្កើតសហាគមន៍អ្នកប្រើប្រាស់ទឹកបច្ចុប្បន្នកំពុងត្រូវបានពិភាក្សានៅទីស្ដីការគណៈរដ្ឋមន្ត្រី។

## ៤. គោលនយោបាយដីធ្លី

បច្ចុប្បន្ន ប័ណ្ណកម្មសិទ្ធដីធ្លីចំនួនជាង ១លានត្រូវបានចេញ។ យោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០០៨របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឲ្យឃើញថា គោលនយោបាយស្តីពីកំណែទម្រង់ដីធ្លីរបស់រាជរដ្ឋាភិបាលកម្ពុជា គឺទទួលបានជោគជ័យក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធដីធ្លីជូនដល់កសិករ ដែលគ្របដណ្តប់លើផ្ទៃដី ១២% នៃផ្ទៃដីស្រែសរុបនៅក្នុងឆ្នាំ ២០០៥ ២០%ក្នុងឆ្នាំ២០០៨ និងរំពឹងថាមានចំនួន ២៤%នៅឆ្នាំ ២០១០។

រាជរដ្ឋាភិបាលកម្ពុជាបានប្រឹងប្រែងបង្កើនដំណើរការនេះ។ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីបានធ្វើការប្រកាសស្តីពីការបង្កើត "គោលនយោបាយទូលំទូលាយស្តីពីដីធ្លី " ផ្អែកលើធាតុចំនួនបីគឺ: រដ្ឋបាលដីធ្លី ការគ្រប់គ្រងដីធ្លី និងការបែងចែកដីធ្លី។

## ៥. ការស្រាវជ្រាវ និងផ្សព្វផ្សាយវិស័យកសិកម្ម

ទោះបីជាថវិកាជាតិដែលបែងចែកសម្រាប់វិស័យកសិកម្មមានចំនួនតិចតួចក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជានៅបន្តប្រឹងប្រែងធានានូវសន្តិសុខស្បៀងជូនប្រជាជន និងធានានូវលំហូរនៃការផ្គត់ផ្គង់គ្រាប់ពូជ ជី និងថ្នាំសំលាប់សត្វល្អិតគ្រប់គ្រាន់សម្រាប់ការដាំដុះស្រូវ។ ស្ថានីយស្រាវជ្រាវជាច្រើនត្រូវបានបង្កើតឡើងនៅក្នុងទីតាំងយុទ្ធសាស្ត្រផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការបង្កើតស្រែពិសោធន៍ និងស្រែគំរូជាច្រើនរាប់រយទៀតផងដែរ។ សៀវភៅផ្សព្វផ្សាយជាច្រើនត្រូវបានបោះពុម្ពនិងចែកផ្សព្វផ្សាយដល់កសិករ។ មានស្រុកចំនួន១៩៣នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងស្រុកនីមួយៗ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មមួយ ឬពីររូប ត្រូវបានចាត់ឲ្យទៅបំពេញការងារនៅពាសពេញតំបន់ជនបទ ដើម្បីផ្តល់ពិតមាន និងបង្រៀនដល់កសិករអំពីបច្ចេកទេសថ្មីៗក្នុងការលើកកំពស់វិស័យកសិកម្ម (តារាង៣)

**តារាង៣: ចំនួនកសិករដែលបានទទួលការបណ្តុះបណ្តាលពីភ្នាក់ងារផ្សព្វផ្សាយកសិកម្ម**

| ឆ្នាំ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|
| ចំនួនកសិករ | ១១.០០០ | ១៥.០០០ | ១៦.០០០ | ២១.០០០ | ២៦.០០០ |

ប្រភព: របាយការណ៍ប្រចាំឆ្នាំ ២០០៨-២០០៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រៅពីការប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក៏មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពផ្សព្វផ្សាយវិស័យកសិកម្មផងដែរ។

## ៦. ការផ្គត់ផ្គង់អគ្គីសនីតាមតំបន់ជនបទ

ភាគច្រើននៃអគ្គីសនីដែលផលិតនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រើប្រាស់នៅក្នុងទីក្រុង និងតំបន់ក្រុងផ្សេងៗ។ ភាគរយនៃការប្រើប្រាស់នៅក្នុងតំបន់ជនបទមានចំនួនតិចតួចណាស់។ កម្ម៉ីបច្ចុប្បន្ន

ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលពីប្រទេសចិនចំនួន ៥០ លានដុលបង្ហាញអំពីការចាប់អារម្មណ៍របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដោះស្រាយបញ្ហានេះ។

**៧.ផ្លូវថ្នល់តំបន់ជនបទ**

ស្ថាប័នពាក់ព័ន្ធជាច្រើន (ក្រសួងអភិវឌ្ឍន៍ជនបទ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងអាជ្ញាធរក្នុងស្រុក) បានចូលរួមនៅក្នុងកិច្ចអភិវឌ្ឍប្រព័ន្ធផ្លូវថ្នល់នៅតាមតំបន់ជនបទ។ ប្រវែងពិតប្រាកដនៃផ្លូវថ្នល់ដែលត្រូវបានសាងសង់ គឺមានការលំបាកក្នុងការទទួលបានណាស់។ ប៉ុន្តែ ទោះបីជាយ៉ាងណាក្តី នៅក្នុងរយៈពេល១០ឆ្នាំកន្លងមក គ្រប់គ្នាអាចកត់សំគាល់ឃើញថា មានផ្លូវថ្នល់ខ្វាត់ខ្វែងជាច្រើននៅតាមតំបន់ជនបទភ្ជាប់ពីភូមិនានាតៅតំបន់ផ្សារ និងកន្លែងសំខាន់ៗផ្សេងទៀតផងដែរ។

**៨. ការផ្តល់ជំនួយដល់កសិករ**

**ក. សមាគម**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមការសហាការជាមួយនឹងអង្គការ FAO បានជួយដល់ការបង្កើតអង្គការកសិករចំនួន ១៤.០០០ ដែលអង្គការមួយមានសមាជិកប្រហែល ២៥រូប ដើម្បីជួយគ្នាទៅវិញទៅមក និងដើម្បីទទួលជំនួយពីរាជរដ្ឋាភិបាលក្នុងទម្រង់ជាហិរញ្ញប្បទានតូចៗ ការផ្ទេរបច្ចេកវិទ្យា។ល។ ដូចគ្នានេះដែរ សហាករកសិកម្មចំនួន ១១៧ ត្រូវបានបង្កើតឡើងហើយ និងទទួលបានជំនួយយ៉ាងច្រើនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សមាជិកសហាករនីមួយៗនឹងទទួលបានផលប្រយោជន៍ពីការផ្ទេរបច្ចេកវិទ្យា កិច្ចសន្យាទីផ្សារកសិកម្ម ការផ្គត់ផ្គង់ធាតុចូលក្នុងតម្លៃទាប និងជំនួយក្នុងការកំណត់អត្តសញ្ញាណអ្នកផ្តល់ឥណទាន។

ថ្មីៗនេះ រាជរដ្ឋភិបាលបានផ្តួចផ្តើមបង្កើតសមាគមន៍រោងម៉ាស៊ីនកិនស្រូវ។ សរុបទៅមានសមាគន៍រោងម៉ាស៊ីនកិនស្រូវខេត្តចំនួន៩ មានសមាជិក៣៥០រូប នៅក្នុងខេត្តសៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សត្វ កំពង់ចាម ព្រៃវែង ស្វាយរៀង កណ្តាល និងខេត្តតាកែវ។

**ខ. ឥណទាន**

ក្រៅពីជំនួយតិចតួចពីរាជរដ្ឋាភិបាលកម្ពុជា ប្រជាកសិករដាំស្រូវ ជាលក្ខណៈទ្រង់ទ្រាយតូចទទួលជំនួយហិរញ្ញប្បទានតិចតួចពីប្រភពផ្សេងទៀតផងដែរ ពីព្រោះតែពួកគេពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានកម្ចី។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ឧស្សាហាកម្មស្រូវ ក្រោយពេលប្រមូលផល បានទទួលជំនួយហិរញ្ញប្បទានលើកទឹកចិត្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ធនាគារអភិវឌ្ឍន៍ជនបទ (RDB) និងក្រុមហ៊ុន Cambodia Green Trade (តារាង៤)។

**តារាង៤: ជំនួយហិរញ្ញវត្ថុពីរាជរដ្ឋាភិបាលកម្ពុជាដល់រោងម៉ាស៊ីនស្រូវ ( ជាលានដុល្លារអាមេរិក/ឆ្នាំ)**

| ទីភ្នាក់ងារ | ២០០៥-២០០៦ | ២០០៦-២០០៧ | ២០០៧-២០០៨ | ២០០៨-២០០៩ |
|---|---|---|---|---|
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២ | ៣ | ១៣ | ១៨ |

| | | | | |
|---|---|---|---|---|
| ធនាគារអភិវឌ្ឍជនបទ | ១ | ១ | ២ | ៥ |
| Cambodian Green Trade | ០ | ០ | ៤ | ៣.៧ |
| សរុប | ៣ | ៤ | ១៩ | ២៦.៧ |

ប្រភព: លោក ម៉ី វ៉ាន់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កម្ចីនេះត្រូវបានប្រើប្រាស់ចំបង សម្រាប់ប្រមូលស្រូវពីកសិករ ដើម្បី:

- កាត់បន្ថយ និងបង្ការការហូរចេញស្រូវក្នុងចំនួនដ៏ច្រើនទៅកាន់ប្រទេសជិតខាង។
- បង្កើនស្តុកផ្ទុកស្រូវ ដើម្បីរក្សាសុវត្ថិភាពស្រូវ។
- បង្កើនបរិមាណកែច្នៃ និងនាំចេញក្នុងទម្រង់ជាអង្ករដែលបានកិនរួច ជាជាងក្នុងទម្រង់ជាស្រូវ។

ប្រហែលជា១០%នៃកម្ចីក៏ត្រូវបានប្រើប្រាស់ សម្រាប់ការកែលំអបរិក្ខារម៉ាស៊ីន និងកែច្នៃផងដែរ។

## ៩. ការវិនិយោគលើវិស័យកសិកម្ម

ចាប់ពីឆ្នាំ ២០០៥មក ការអនុម័តលើការវិនិយោគអាជីវកម្មថ្មីៗបានបន្តកើនឡើងជាបន្តបន្ទាប់។ យោងតាមតួលេខទទួលបានពីក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា (CDC) បានឲ្យដឹងថា ការអនុម័តសរុបលើគម្រោងវិនិយោគ ក្នុងឆ្នាំ២០០៦ មានចំនួន ៣៩៧,៩ លានដុល្លារអាមេរិក កើនឡើងជាបីដងនៃចំនួនតែ ៩៦២,៤ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០០៥ (តារាង៥)។ ប្រទេសចិននៅតែជាវិនិយោគិនបរទេសនាំមុខគេ ដែលបានវិនិយោគក្នុងទឹកប្រាក់ចំនួន ៧៦៣ លានដុល្លារអាមេរិក បន្ទាប់មកប្រទេសរុស្ស៊ី ក្នុងទឹកប្រាក់ចំនួន ២៧៨ លានដុល្លារអាមេរិក ប្រទេសថៃ ១០២ លានដុល្លារអាមេរិក ប្រទេសកូរ៉េខាងត្បូង ៧៩ លានដុល្លារអាមេរិក និងប្រទេសអាមេរិកចំនួន ៦២ លានដុល្លារអាមេរិក។ ស្ថិតិរបស់ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ក៏បានបង្ហាញផងដែរថា ការវិនិយោគជាចំបងធ្វើឡើងលើវិស័យសំណង់ រ៉ែ សំលៀកបំពាក់ ថាមពល និងស៊ីម៉ងត៍។

នៅក្នុងឆ្នាំ ២០០៦ ការវិនិយោគលើវិស័យកសិកម្មមានត្រឹមតែ ៣៨៩,១ លានដុល្លារអាមេរិក ប៉ុណ្ណោះ ដែលនេះ គឺជាការវិនិយោគតិចតួចបំផុតក្នុងចំណោមវិស័យទាំងអស់។ ស្ថានភាពនៅបន្តដដែលសម្រាប់ឆ្នាំ ២០០៧ ឆ្នាំ ២០០៨ និងឆ្នាំ ២០០៩។ ទោះបីជាប្រជាជនកម្ពុជាភាគច្រើនរស់នៅក្នុងតំបន់ជនបទ និងពេងផ្អែកទៅលើការដាំដុះស្រូវសម្រាប់ចិញ្ចឹមជីវិតក៏ដោយ ក៏វិស័យនេះភាគច្រើននៅមិនទាន់មានការអភិវឌ្ឍនៅឡើយ ដែលនេះជាការឆ្លុះបញ្ចាំងអំពីការវិនិយោគឯកជន និងសាធារណៈក្នុងកម្រិតយ៉ាងទាបមួយ នៅក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក។ ទោះបីជាមានការធ្លាក់ចុះក្នុងការរួមចំណែកដល់ GDP ក៏ដោយ ក៏វិស័យនេះនៅបន្តផ្តល់ការងារដល់ប្រជាជន កម្ពុជាភាគច្រើនដដែល ជាពិសេស ប្រជាជនក្រីក្រ។ ការវិនិយោគដែលបង្កើនដល់ផលិតផលកសិកម្មនឹងមានផលប្រសិទ្ធភាពខ្លាំងទៅលើសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ។ ធនាគារ

ពិភពលោក នៅឆ្នាំ២០០៦ បានធ្វើការសន្និដ្ឋានថា ប្រសិនបើកំណើនកសិកម្មអាចសម្រេចបាន ៤%ក្នុង១ឆ្នាំ នោះប្រទេសកម្ពុជានឹងអាចសម្រេចបាន តាមគោលដៅអភិវឌ្ឍន៍សហវត្សរបស់ខ្លួន ដែលបានកំណត់ថា កាត់បន្ថយភាពក្រីក្រឲ្យបានពាក់កណ្ដាលនៅត្រឹមឆ្នាំ ២០១៥។

**តារាង៥: ការវិនិយោគតាមវិស័យ ដែលបានអនុម័តដោយគណៈកម្មការវិនិយោគកម្ពុជា ឆ្នាំ ២០០០-២០០៨(លានដុល្លារ/ឆ្នាំ)**

| វិស័យ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩កក្កដ |
|---|---|---|---|---|---|---|---|---|---|---|
| កសិកម្ម | ៩,៨ | ០,៤ | ៤០,៣ | ៣,៧ | ១២,៣ | ១៧,៧ | ៣៨៩,១ | ៥៧,៥ | ១០៦,៧ | ៣១៩ |
| ឧស្សាហកម្ម | ៥៩,៤ | ៨៥,៩ | ៤៨,៩ | ៧៤,៦ | ១០៦,៣ | ៨២៧,៨ | ៥៣៩,៥ | ៣៨៣,៨ | ៧១៥,៩ | ៩៩ |
| សេវាកម្ម | ៦៩,១ | ៤៤,៦ | ៩៨,២ | ៤៦,៤ | ៣៥,៩ | ៣៦,៩ | ២.២២៤,៨ | ៥៨២,៤ | ១.២៩២,២ | ៤៥៨ |
| ទេសចរណ៍ | ៧៩,៨ | ៧៣,៨ | ៤៧,១ | ១០០,០ | ៥៥,៩ | ៨០,០ | ៣១៤,៥ | ៩០២,០ | ៨.៧៧៦,៣ | ៣៥៨ |
| សរុប | ២១៨,០ | ២០៤,៧ | ២៣៤,៦ | ២២៤,៧ | ២១០,៤ | ៩៦២,៤ | ៣.៤៦៧,៩ | ១.៩២៥,៧ | ១០.៨៩១,១ | ១.២៣៤ |

ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០០៩

ក្នុងចំណោមក្រុមហ៊ុន ឬគម្រោងដែលមានប្រតិបត្តិការ និងសកម្មភាពចំនួន ៨៧៤ ប្រសិនបើបូក ចាប់ពីឆ្នាំ ២០០៤ ដល់ ២០០៧ មានក្រុមហ៊ុនចំនួន៥០ (៥,៧ %) វិនិយោគលើវិស័យកសិកម្ម ៦៤៩ ក្រុមហ៊ុន (៧៣,៧ %) លើវិស័យឧស្សាហកម្ម ៨២ ក្រុមហ៊ុន (៩,៤ %) ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ/សេវាកម្ម និង ៩៣ ក្រុមហ៊ុន (១០,៦ %) លើវិស័យទេសចរណ៍។

**១០. ពាណិជ្ជកម្មអន្តរជាតិ**

ប្រទេសកម្ពុជាបានចូលជាសមាជិកអាស៊ានក្នុងឆ្នាំ ១៩៩៩។ កិច្ចសហប្រតិបត្តិការ និងសមាហរណកម្មជាមួយអាស៊ាន ធ្វើឲ្យប្រទេសកម្ពុជាទទួលបាននូវការរួមកំលាំងជាសក្តានុពលពីទំនាក់ទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគដែលអាចជួយជំរុញដល់កំណើនសេដ្ឋកិច្ច និងការលុបបំបាត់ភាពក្រីក្រយ៉ាងឆាប់រហ័ស។ បន្ទាប់ពីការចូលជាសមាជិកអាស៊ានរបស់ខ្លួនរាជរដ្ឋាភិបាលកម្ពុជាបានធ្វើកិច្ចការជាច្រើនដើម្បីជំរុញឲ្យប្រទេសកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ ជាលទ្ធផល ប្រទេសកម្ពុជាបានក្លាយជាសមាជិកទី ១៤៨ របស់អង្គការពាណិជ្ជកម្ម ពិភពលោក នាថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៤ ។ ដើម្បីធានាថាការចូលរួមជាសមាជិកអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក នឹងផ្តល់នូវអត្ថប្រយោជន៍ដល់ប្រទេសកម្ពុជា រាជរដ្ឋាភិបាលបាន បង្កើនល្បឿនក្នុងកំណើនសេដ្ឋកិច្ចរបស់ខ្លួន និងកំណែទម្រង់ចាំបាច់ផ្សេងទៀត ដែលរួមមានអភិបាលកិច្ចល្អ ក្នុងផ្នែករដ្ឋបាល ក្របខ័ណ្ឌច្បាប់ និងយុត្តិធម៌ និងការគ្រប់គ្រងហិរញ្ញវត្ថុ។

ក្នុងដំណើរការកំណែទម្រង់នេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់រួចមកហើយ នូវកម្មវិធីកំណែទម្រង់ច្បាប់ និងបណ្តុះបណ្តាលសម្មត្ថភាព ដែលមានទិសដៅពង្រឹងបរិយាកាសវិនិយោគ និងអាជីវកម្ម សម្រាប់ការអភិវឌ្ឍ វិស័យពាណិជ្ជកម្ម នៅក្នុងកម្មវិធីផ្តួចផ្តើមជាច្រើន។

កម្មវិធីទីមួយនោះគឺ "កម្មវិធីការងាររបស់រាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីចូលរួមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក"។ ទីពីរគឺ "ផែនការសកម្មភាព១២ចំណុចសម្រាប់សម្រួលដល់ផ្នែកពាណិជកម្ម"។ ទីបីគឺ "ផែនការសកម្មភាព១០ចំណុចស្តីពីការសម្របសម្រួល និងជំរុញការវិនិយោគ។ " ចំណុចល្អមួយទៀតនោះគឺ វិធានការអនាម័យ និងភូតគាមអនាម័យ គឺជាបញ្ហាធូរស្រាលនៅក្នុងផ្នែក ពាណិជ្ជកម្មស្រូវអន្តរជាតិ។ លើសពីនេះទៅទៀតសហគមន៍អឺរ៉ុបទើបបានផ្តល់ការលើកលែងពន្ធ និងកូតាសម្រាប់អង្ករកម្ពុជាផងដែរ។

**១១. ការនាំចេញអង្ករ**

ទីផ្សារនាំចេញចម្បងនាពេលបច្ចុប្បន្នសំរាប់អង្ករកម្ពុជារួមមាន ប្រទេស បេលហ្សិក ប្រទេសបារាំង ប្រទេសម៉ាឡេស៊ី សហរដ្ឋអាមេរិក និងប្រទេសអូស្ត្រាលី។ ការនាំចេញស្រូវក្រៅផ្លូវការយ៉ាងច្រើនទៅកាន់ប្រទេសវៀតណាម និងប្រទេសថៃ មិនមានកំណត់ត្រាច្បាស់លាស់នោះទេ (តារាងលេខ ៦)។ វាក្យស័ព្ទ "នាំចេញ"នៅក្នុងតារាងលេខ ៦ រាប់បញ្ចូលទាំងការនាំចេញអង្ករ ឬស្រូវផ្លូវការ និងក្រៅផ្លូវការ។ ទស្សនកិច្ចនាពេលថ្មីៗកន្លងទៅនេះគណៈប្រតិភូមកពីប្រទេសអារ៉ាប់រួមអេមីរាត ដើម្បីពិនិត្យមើលលទ្ធភាពនៃការសន្តិសុខស្បៀងក្នុងផ្នែកអាហារមូលដ្ឋានចំនួន ១៥ មុខ នោះ គឺជាការងារមួយគួរឲ្យលើកទឹកចិត្តខ្លាំងណាស់។ សូមកត់សំគាល់ថា ប្រទេសអារ៉ាប់រួមអេមីរ៉ាតប្រើប្រាស់អង្ករអស់ចំនួន ៨០០.០០០ តោនក្នុងមួយឆ្នាំ។ នេះគឺជាទីផ្សារប្រកបដោយសក្តានុពលមួយយ៉ាងល្អសំរាប់ប្រទេសកម្ពុជា។

**តារាង៦: ប្រទេសកម្ពុជា: ទិន្នផលស្រូវ តម្រូវការក្នុងស្រុក និងការនាំចេញ (០០០ តោន) ឆ្នាំ២០០១-២០០៩ (គម្រោង)**

| បរិយាយ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|---|---|---|---|---|
| ទិន្នផល | ៤.០៩៩ | ៣.៨២៣ | ៤.៧១១ | ៤.១៧០ | ៥.៩៨៥ | ៦.២៦៣ | ៦.៦៧៤ | ៦.៨៣១ | ៧.០៦១ |
| តំរូវការក្នុងស្រុក | ៣.២៨៤ | ៣.៣៤៩ | ៣.៥៦ | ៣.៣១៩ | ៣.៥០៩ | ៣.៦០៣ | ៣.៧០៨ | ៣.៧៨០ | ៣.៨៥៩ |
| - ការប្រើប្រាស់ | ២.៩៩៧ | ៣.០៨២ | ៣.០២៦ | ៣.០២៨ | ៣.០៩០ | ៣.១៦៥ | ៣.២៤០ | ៣.៣០២ | ៣.៣៦៥ |
| - គ្រាប់ពូជ | ២៨៧ | ២៦៨ | ៣៣០ | ២៩២ | ៤១៩ | ៤៣៨ | ៤៦៧ | ៤៧៨ | ៤៩៤ |
| នាំចេញ | ៥៦៩ | ២៤៤ | ១.០៧៣ | ៦០០ | ២.១១៨ | ២.២៨៤ | ២.៥៦៦ | ២.៦៩១ | ២.៧៧៩ |
| នាំចេញ (ស្មើនឹងអង្ករ) | ៣៦៤ | ១៥៦ | ៦៨៧ | ៣៨៤ | ១.៣៥៥ | ១.៤៦២ | ១.៦៤២ | ១.៦៩១ | ១.៧៧៨ |

ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (តំរូវការក្នុងស្រុក និងការនាំចេញគឺជាបរិមាណតាមការប៉ាន់ប្រមាណ)

ថ្មីៗនេះផងដែរ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយនឹងក្រុមហ៊ុន Green Trade Co. របស់ប្រទេសកូរ៉េខាងត្បូង ដើម្បីពង្រីកពាណិជ្ជកម្មអង្ករទៅកាន់ប្រទេសកូរ៉េខាងត្បូង និងទីផ្សារប្រកបដោយសក្តានុពលផ្សេងទៀត តាមរយៈបច្ចេកវិទ្យាកិន ការដាក់យីហោ និងការវិចខ្ចប់កាន់តែល្អសម្រាប់ការនាំចេញ។

ស្ថានភាពស្រូវបច្ចុប្បន្ននៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបានពិពណ៌នានៅក្នុងផ្នែកនេះឆ្លុះបញ្ចាំងអំពីកិច្ចប្រឹងប្រែងយ៉ាងខ្លាំងក្លារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផលិត ការស្វែងរកទីផ្សារ និងការកែច្នៃអង្ករ។

## ៣. បញ្ហាប្រឈម និងឧបសគ្គ

ទោះបីជាមានការខិតខំប្រឹងប្រែង និងកែលម្អប្រកបដោយចីរភាពយ៉ាងនេះក៏ដោយ ក៏ព្រះរាជាណាចក្រកម្ពុជានៅបន្តជួបប្រទះបញ្ហាប្រឈម និងឧបសគ្គជាច្រើន នៅក្នុងការអភិវឌ្ឍអង្កររបស់ខ្លួន ដែលជាដំណាំពិសេសមួយក្នុងចំណោមដំណាំពិសេសៗផ្សេងទៀត សម្រាប់កំណើនសេដ្ឋកិច្ចផងដែរ។ ផលិតភាព និងពាណិជ្ជកម្មស្រូវរបស់ប្រទេសកម្ពុជាត្រូវបានរាំងស្ទះដោយកត្តាជាច្រើនៈ

១. ការបែងចែកថវិការជាតិមិនបានគ្រប់គ្រាន់ដល់វិស័យកសិកម្ម។ មានតែប្រហែលជា២,២%នៃថវិកាជាតិប៉ុណ្ណោះត្រូវបានបែងចែកសម្រាប់វិស័យកសិកម្ម ក្នុងពេលដែលប្រជាជន ៨៥%កំពុងរស់នៅតំបន់ជនបទ។

២. ទិន្នផលទាបប្រហែល ២,៨៦តោន/ហិកតា ក្នុង១ឆ្នាំ ប្រៀបធៀបទៅនឹងប្រទេសវៀតណាម ( ៥,៦៣ តោន/ហិកតា) ឡាវ (៣,៣តោន/ហិកតា) និងថៃ (៤,0 តោន/ហិកតា)។

៣. លទ្ធភាពតិចតួចក្នុងការទទួលបានធនធានវិស័យកសិកម្មៈ ជី ថ្នាំសំលាប់សត្វល្អិត គ្រឿងចក្រ និងគ្រាប់ពូជល្អ។

៤. ហេដ្ឋារចនាសម្ព័ន្ធជនបទនៅខ្វះខាតៈ ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ អគ្គីសនី ដែលបណ្តាលឲ្យថ្លៃចំណាយក្នុងការផលិតមានកម្រិតខ្ពស់។

៥. ការផ្តល់មូនិធិសម្រាប់ការស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្មនៅខ្វះខាតនៅឡើយ។

៦. ការផ្លាស់ប្តូរបច្ចេកទេសមានតិចតួចនៅថ្នាក់សហគមន៍ ដើម្បីទទួលយកនូវបច្ចេកវិទ្យាទំនើបៗ និងការអនុវត្តល្អបំផុត ដោយសារការខ្វះខាតនូវភ្នាក់ងារផ្សព្វផ្សាយវិស័យកសិកម្មនោថ្នាក់ឃុំ។

៧. លទ្ធភាពទទួលបានឥណទាន និងមីក្រូហិរញ្ញវត្ថុនៅមានកំរិត នៅតាមជនបទសំរាប់ប្រជាកសិករដាំស្រូវជាលក្ខណៈទ្រង់ទ្រាយតូច។

៨.សមត្ថភាពវិនិយោគ ឬចំណាប់អារម្មណ៍ក្នុងការវិនិយោគលើវិស័យស្រូវដោយវិនិយោគគិនក្នុងស្រុក ក៏ដូចជាអន្តរជាតិ នៅមានគំនិតស្ទួចស្ទើង។

៩.វិស័យកសិពាណិជ្ជកម្ម និងកសិសហគ្រាសនៅមានកំរិតទន់ខ្សោយជាពិសេសការស្តុក សមត្ថភាពកែច្នៃ និងមានគុណភាព។

១០.ឧបសគ្គក្នុងការនាំចេញដោយសាររបាំងបច្ចេកទេស (បទដ្ឋានគុណភាព ការគ្រប់គ្រងគុណភាព វិញ្ញាបនបត្រ័បញ្ជាក់គុណភាព) ដែលដាក់ដោយប្រទេសនាំចេញអង្ករ។ លើសពីនេះទៀត នៅក្នុងប្រទេសកម្ពុជា មានដំណាក់កាលចាំបាច់ជាច្រើនដែលត្រូវបំពេញឲ្យបាន មុននឹងអាចនាំអង្ករចេញ ដូចជា:

→ កិច្ចសន្យាលក់

→ ឯកសារដឹកជញ្ជូន

→ ឯកសារនាំចេញ ដែលដឹកនាំដោយអជ្ញាធរគយ និងក្រសួងពាក់ព័ន្ធផ្សេងទៀត:

– វិញ្ញាបនប័ត្រប្រភពទំនិញ (ក្រសួងពាណិជ្ជកម្ម)

– វិញ្ញាបនប័ត្របទដ្ឋាន (ក្រសួងឧស្សាហាកម្ម រ៉ែ និងថាមពល)

– វិញ្ញាបនប័ត្រអនាម័យ និងភូតគាមអនាម័យ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)

– ប្រតិវេទន៍គយ (ទីចាត់ការគយ)

– អាជ្ញាប័ណ្ណនាំចេញ (ក្រសួងពាណិជ្ជកម្ម)

– លិខិតអនុញ្ញាតនាំចេញ (ក្រសួងពាណិជ្ជកម្ម)។

នៅពេលដែលដំណើរការនេះចប់សព្វគ្រប់ ក្រុមហ៊ុននាំចេញអង្ករមួយត្រូវចំណាយប្រហែល ២៥ ដុល្លារ ទៅ ៤៥ដុល្លារ/តោន និងប្រើប្រាស់ពេលវេលាយូរ បើប្រៀបធៀបនឹងប្រទេសវៀតណាម ដែលការចំណាយមានប្រហែលពី ១០ ដុល្លារ ទៅ ១៥ ដុល្លារ/តោន និងប្រើប្រាស់រយៈពេលតិចតួចប៉ុណ្ណោះ។

## ៤. ការអនុវត្តភាព

រាជរដ្ឋាភិបាលអាចជំនះបាននៅរាល់បញ្ហាប្រឈម និងឧបសគ្គខាងលើ តាមរយៈចំណាត់ការសមស្រប ដូចជា:

**១**. បង្កើនថវិកាបែងចែកសំរាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ អាទិទេពគួរត្រូវបានផ្តល់ជូនដល់ផ្នែកស្រាវជ្រាវ និងអភិវឌ្ឍ និងការជ្រើសរើសភ្នាក់ផ្សព្វផ្សាយកសិកម្មឲ្យមានចំនួនគ្រប់គ្រាន់។

**២**. បង្កើនទិន្នផលស្រូវតាមរយៈការធ្វើកសិកម្មដែលប្រើប្រាស់សម្ភារៈកំរិតខ្ពស់ ដូចជាការដាំដំណាំតែមួយមុខ និងការជ្រើសរើសគ្រាប់ពូជតាមបែបទំនើប ជី ថ្នាំសម្លាប់សត្វល្អិត និងប្រព័ន្ធស្រោចស្រព។ គួរមានការប្រុងប្រយ័ត្នដើម្បីបញ្ចៀសនូវបញ្ហាធ្ងន់ធ្ងរទៅលើបរិស្ថានដែលកើតឡើងពីការប្រើប្រាស់ធាតុចូលទាំងនេះមិនសមស្រប។

**៣**. បង្កើនមុលដ្ឋានដីសម្រាប់ផលិតកម្មស្រូវ ជាពិសេសនៅក្នុងបណ្តាខេត្តដែលផលិតស្រូវធំៗ (តារាង៧)

**តារាង៧: ផ្ទៃដី និងផ្ទៃដីដាដុះតាមខេត្ត (គិតជាពាន់ហិចតា)**

| ខេត្ត | ផ្ទៃដី | ផ្ទៃដីដាំដុះ | | | ទិន្នផល | | |
|---|---|---|---|---|---|---|---|
| | | ២០០៦ | ២០០៧ | ២០០៨ | ២០០៦ | ២០០៧ | ២០០៨ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| បន្ទាយមានជ័យ | ៦៦៧,៩ | ២១៩,៦ | ២១០,៨ | ២១០,០ | ២,២ | ២,១ | ២,៥ |
| បាត់ដំបង | ១.១៧០,២ | ២៤៦,៥ | ២៤៣,១ | ២៤១,០ | ២,៦ | ២,៣ | ២,៦ |
| កំពង់ចាម | ៩៧៩,៩ | ២១៧,៥ | ២១៩,៨ | ១៦៥,០ | ៣,០ | ៣,៤ | ២,៨ |
| កំពង់ឆ្នាំង | ៥៥២,១ | ១២៤,០ | ១២៧,៧ | ១០៣,២ | ២,៣ | ២,៤ | ២,៥ |
| កំពង់ស្ពឺ | ៧០១,៧ | ១០៩,១ | ១០៩,១ | ១១០,០ | ២,៣ | ២,៤ | ២,២ |
| កំពង់ធំ | ១.៣៨១,៤ | ១៦៦,៨ | ១៧២,៧ | ១៦១,០ | ២,៤ | ២,៥ | ២,០ |
| ព្រៃវែង | ១.៣៧៨,៨ | ៣១៧,៩ | ៣២៥,៧ | ២៥០,០ | ២,៦ | ៣,០ | ២,៧ |
| សៀមរាប | ១.០៧៨,២ | ១៩០,៧ | ១៨៨,១ | ១៧៩,០ | ១,៩ | ១,៨ | ១,៨ |
| ស្វាយរៀង | ១.១០៩,២ | ១៦១,៣ | ១៧៤,៨ | ១៦០,០ | ១,៧ | ២,៣ | ២,១ |
| តាកែវ | ២៩៦,៦ | ២៤៧,៣ | ២៤៦,៤ | ១៧០,០ | ៣,២ | ៣,៣ | ២,៨ |

ប្រភព: របាយការណ៍ស្ថិតិប្រចាំឆ្នាំ ២០០៨

ដូចមានបង្ហាញនៅក្នុងតារាង៧ខាងលើ ខេត្តនីមួយៗនៅតែមានសក្តានុពលក្នុងការបង្កើនមូលដ្ឋានផ្ទៃដីសម្រាប់ផលិតស្រូវ។ ទោះជាយ៉ាងណាក្តី ក៏ការយកចិត្តទុកដាក់គួរផ្តោតទៅលើផលិតកម្មស្រូវប្រាំង ព្រោះវាផ្តល់ទិន្នផលខ្ពស់។

**៤.** បង្កើនការផ្តល់ប្រាក់កម្ចីដោយប្រើប្រាស់ប្រភេទឧបករណ៍ឥណទានសមស្របសម្រាប់កសិករដាំស្រូវជាលក្ខណៈទ្រង់ទ្រាយតូច ដែលជួបការលំបាកក្នុងការបំពេញតាមលក្ខខ័ណ្ឌតឹងតែងរបស់ស្ថាប័នផ្តល់ប្រាក់កម្ចី។

**៥.** បង្កើនប្រាក់កម្ចីដោយប្រើប្រាស់ប្រភេទឧបករណ៍ឥណទានសមស្របសម្រាប់រោងម៉ាស៊ីនកិនស្រូវ ដើម្បីកែលម្អគ្រឿងបរិក្ខារបច្ចេកទេសសម្រាប់ដំណើរការកិនស្រូវ និងឃ្លាំងស្តុករបស់ម៉ាស៊ីនកិនស្រូវទាំងនោះ និងដើម្បីបង្កើនការប្រមូលស្រូវពីប្រជាកសិករ។

**៦.** ពង្រឹងទំនាក់ទំនងរវាងកសិករដាំស្រូវ និងម៉ាស៊ីនកិនស្រូវ ដើម្បីបង្កលក្ខណៈងាយស្រួលឲ្យដំណើរការប្រព្រឹត្តទៅប្រកបដោយភាពរលូន ចាប់ពីការផលិតស្រូវរហូតដល់ការកិន និងការនាំចេញអង្ករ។

**៧.** អនុវត្តឲ្យបានពេញលេញ និងឆាប់រហ័សនូវ "១២ ចំណុចនៃផែនការសកម្មភាពសម្រាប់ការសម្រួលពាណិជ្ជកម្ម" និង "១០ ចំណុចនៃផែនការសកម្មភាពស្តីពីការសម្របសម្រួល និងការជំរុញការវិនិយោគ"។

**៨.** កាត់បន្ថយលក្ខខណ្ឌស្មុគស្មាញនៃការនាចេញអង្ករ។

**៩.** អភិវឌ្ឍភាពជាដៃគូ ជាមួយវិស័យឯកជនដែលនឹងជួយផ្តល់នូវការឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ជូនដល់កសិករ និងរោងម៉ាស៊ីនកិនស្រូវ។

**១០.** ពង្រឹងទីផ្សារដែលមានស្រាប់ និងពង្រីកទីផ្សារថ្មីៗសម្រាប់ការនាំចេញអង្ករ។

## ៥. ការគាំទ្រគាំហែង

ការគាំទ្រកាំហែងធំៗនាពេលបច្ចុប្បន្នចំពោះជោគជ័យក្នុងការអភិវឌ្ឍស្រូវជាទំនិញកសិកម្មដ៏សំខាន់មួយនៅកម្ពុជា គឺកង្វះការឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុ:

→ ដើម្បីឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចអនុវត្តនូវភារកិច្ចរបស់ខ្លួននៅក្នុងកិច្ចការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងផ្សព្វផ្សាយព័ត៌មានដល់ប្រជាកសិករ។

→ដើម្បីឲ្យប្រជាកសិករដាំស្រូវជាលក្ខណៈទ្រង់ទ្រាយតូចអាចអនុវត្តនូវបច្ចេកវិទ្យាថ្មីៗនៅក្នុងវាលស្រែរបស់ពួកគេ។

→ ដើម្បីឲ្យរោងម៉ាស៊ីនកិនស្រូវអាចកែលម្អគ្រឿងបរិក្ខារដំណើរការកិនស្រូវរបស់ពួកគេឲ្យសមស្របតាមលក្ខណៈបទដ្ឋានអន្តរជាតិ និងដើម្បីប្រមូលស្រូវពីកសិករឲ្យបានទាន់ពេលវេលាសមស្រប។

## ៦. អនុសាសន៍ជាក់ស្តែង

ចតុយុទ្ធសាសន៍ (យុទ្ធសាសន៍ទាំង៤) ខាងក្រោមនេះត្រូវបានរៀបរៀងឡើងជាអនុសាសន៍សម្រាប់ធ្វើការអភិវឌ្ឍដំណាំស្រូវ ជាវិស័យដ៏សំខាន់មួយ ក្នុងការរួមចំណែកដល់ការជំរុញកំណើនសេដ្ឋកិច្ចនៅកម្ពុជា÷

### ១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ការចំណាយនាពេលបច្ចុប្បន្នដែលបែងចែកសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង្កើនឲ្យបានយ៉ាងតិច៣%នៃការចំណាយសរុបនាពេលបច្ចុប្បន្នសម្រាប់:

i. ជាជំនួយដល់ប្រជាកសិករដាំស្រូវជាលក្ខណៈទ្រង់ទ្រាយតូចក្នុងទម្រង់ជាកម្ចីមីក្រូដោយអត្រាការប្រាក់ទាប តាមរយៈសមាគមកសិករចំនួន ១៤.០០០ និងសហករណ៍កសិកម្មចំនួន ១១៧ដែលមានស្រាប់

ii. ជាជំនួយឧបត្ថម្ភដល់ប្រតិបត្តិការរបស់ស្ថានីយស្រាវជ្រាវដែលមានស្រាប់ (មិនបន្ថែមអាគារថ្មី) តាមរយៈការបំពាក់បំប៉នជូនដល់អ្នកវិទ្យាសាស្ត្រដែលមានស្រាប់ ដើម្បីក្លាយខ្លួនជាអ្នកវិទ្យាសាស្ត្រ "ជំនាញ" នៅក្នុងផ្នែកផ្សេងៗ តាមតម្រូវការចាំបាច់ និងផ្តល់នូវឧបករណ៍ និងគ្រឿងបរិក្ខារចាំបាច់បន្ថែមផ្សេងទៀត។ CARDI ក៏គួរត្រូវបញ្ចូលទៅក្នុងចំណែកនៃការចំណាយថវិកានេះផងដែរ។

iii. ជ្រើសរើស និងបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មបន្ថែមទៀត ដើម្បីឲ្យមានវត្តមាននៅគ្រប់ឃុំទាំងអស់។ បច្ចុប្បន្ននេះមានឃុំ ១.៦២១ ដែលមានប្រជាកសិករភាគច្រើនកំពុងរស់នៅ និងដាំដុះស្រូវ។ ការបណ្តុះបណ្តាលនេះគួររៀបចំធ្វើឡើងនៅសាលាកសិកម្មព្រែកលាបក្នុងកម្មវិធីបណ្តុះបណ្តាល ដែលមានរយៈពេលតិចជាង (២)ឆ្នាំ។ មធ្យោបាយដឹកជញ្ជូន

(ម៉ូតូ) គួរត្រូវបានផ្តល់ជូនដល់ភ្នាក់ងារទាំងនេះដើម្បីឲ្យពួកគេអាចធ្វើដំណើរទៅជួយកសិករបានយ៉ាងជិតដល់ និងទៀងទាត់។

## ២. កសិករដាំស្រូវជាលក្ខណៈទ្រង់ទ្រាយតូច

រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាអាច:

i. លើកកំពស់សមាគមរបស់ពួកគេតាមរយៈការបណ្តុះបណ្តាលថ្មីៗ និងការអង្កេតតាមដានជាទៀងទាត់ ប្រសិនបើកញ្ចប់លើកទឹកចិត្តផ្នែកហិរញ្ញវត្ថុត្រូវបានផ្តល់ជូន។

ii. អប់រំសមាជិកសមាគមឲ្យយល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ នៅក្នុងកិច្ចសន្យាដែលធ្វើឡើងជាមួយរោងម៉ាស៊ីនកិនស្រូវ និងដៃគូផ្សេងៗទៀត។

iii. បង្កើនប្រាក់កម្ចីសម្រាប់កសិករដាំស្រូវជាលក្ខណៈទ្រង់ទ្រាយតូច ដែលនាពេលកន្លងមកពួកគាត់បានជួបប្រទះនូវការលំបាកក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវរបស់ស្ថាប័នផ្តល់ប្រាក់កម្ចី។

## ៣. រោងម៉ាស៊ីនកិនស្រូវ

វិធានការមួយចំនួនមានដូចជា:

i. ការទទួលបានប្រាក់កម្ចីរបស់រោងម៉ាស៊ីនកិនស្រូវមានលក្ខណៈសមរម្យហើយ ប៉ុន្តែរោងម៉ាស៊ីនកិនស្រូវនៅត្រូវការប្រាក់កម្ចីថែមទៀត ដើម្បីទិញស្រូវឲ្យបានទាន់ពេលវេលា និងដើម្បីលើកកំពស់គុណភាពគ្រឿងបរិក្ខារដំណើរការកិនស្រូវរបស់ពួកគេ។

ii. អនុស្សរណៈយោគយល់មួយដែលត្រូវបានចុះហត្ថលេខាកាលពីពេលថ្មីៗរវាងធនាគារកាណាឌីយ៉ា ជាមួយនឹងធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ( IDCC ) គួរត្រូវបានប្រើប្រាស់ជាអនុស្សរណៈគំរូមួយសម្រាប់ធនាគារ និងស្ថាប័នផ្តល់ប្រាក់កម្ចីផ្សេងៗទៀត។ តាមរយៈអនុស្សរណៈនេះ បណ្តាញឥណទានមួយត្រូវបានបង្កើតឡើង ក្នុងនោះធនាគារកាណាឌីយ៉ា (៣ លានដុល្លារ) ធនាគារពាណិជ្ជកម្មក្រៅប្រទេស (២ លានដុល្លារ) និងធនាគារ IDCC (២៨ លានដុល្លារ) សម្រាប់ឲ្យធនាគារអភិវឌ្ឍជនបទផ្តល់កម្ចីលើវិស័យកសិកម្ម។

iii. សមាគមរោងម៉ាស៊ីនកិនស្រូវគួរបង្កើតទំនាក់ទំនងជាមួយសមាគមកសិករដាំស្រូវ និងសហករណ៍ស្រូវអង្ករ ដើម្បីពង្រឹងបណ្តាញពាណិជ្ជកម្មរបស់ពួកគេ និងសង្វាក់តម្លៃគ្រប់គ្រាន់។ គំរូដែលប្រើប្រាស់នាពេលបច្ចុប្បន្ននេះរួមមាន ការចុះកិច្ចសន្យារវាងម៉ាស៊ីនកិនស្រូវឯកជន និងកសិករដាំស្រូវជាលក្ខណៈទ្រង់ទ្រាយតូច ដើម្បីផលិតស្រូវមួយចំនួន។ គ្រាប់ពូជត្រូវបានផ្តល់ជូនដោយរោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញ ដែលបានផ្តល់ផងដែរនូវធាតុចូលចាំបាច់ផ្សេងៗទៀតដល់កសិករ ដូចជា ជី ថ្នាំសំលាប់សត្វល្អិត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ។ បន្ទាប់មក ដំណាំដែលទទួលបានជាទិន្នផលនឹងត្រូវបានទិញ ដាក់ផ្លាកយីហោកិន និងនាំចេញស្របតាមបទដ្ឋានដែលកំណត់ឡើងនៅលើទីផ្សារអន្តរជាតិ។

ការរៀបចំប្រភេទនេះ គួរត្រូវបានលើកទឹកចិត្ត និងពង្រីក ពីសមាគមរោងម៉ាស៊ីនកិនស្រូវ ពីព្រោះការនេះមានគុណប្រយោជន៍ ដោយមិនចាំបាច់ទាមទារជំនួយច្រើនពីរាជរដ្ឋភិបាល ដើម្បីចាប់ផ្តើមដំណើរការនោះទេ។

iv. ដោយមានជំនួយពីរាជរដ្ឋាភិបាលកម្ពុជា សមាគមរោងម៉ាស៊ីនកិនស្រូវគួរស្វះស្វែងពង្រីក ទីផ្សារអង្ករបស់ខ្លួនទៅកាន់ប្រទេសថ្មីៗទៀត ដូចជា ប្រទេសនីហ្សេរីយ៉ា ប៊ុលការី អ៊ីរ៉ាក់ អ៊ីតាលី ចក្រភពអង់គ្លេស អាល្លឺម៉ង់ កូរ៉េខាងត្បូង សេនេហ្គាល់ អាហ្វ្រិកខាងត្បូង អារ៉ាប់រួមអេមីរ៉ាត ជប៉ុន ប៉ាពួញូវហ្គីនេ អតីតសហភាពសូវៀត និងប្រទេសអឺរ៉ុបផ្សេងៗទៀត។ លើសពីនេះទៀតនោះ សមាគមរោងមាស៊ីនកិនស្រូវ គួរធ្វើសហប្រតិបត្តិការឲ្យបានជិតស្និទ្ធ ជាមួយប្រជាកសិករដាំស្រូវ ដើម្បីលើកកំពស់ទីផ្សារបន្ទាប់បន្សំទីពីរ ដែលជាទីផ្សារសម្រាប់ ស្រូវសរីរាង្គ។ ទីផ្សារស្រូវសរីរាង្គនៅក្នុងវិស័យកសិកម្មបានកើនឡើងក្នុងអត្រាពី ៨% ទៅ ១០% នៅក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅនេះ។ ទីផ្សារសរីរាង្គផ្តល់អត្ថប្រយោជន៍ពិត ប្រាកដដល់កសិករ តាមរយៈការចំណាយទាបលើជី និងថ្នាំសំលាប់សត្វល្អិត ហើយទិន្នផល ស្រូវលក់បានថ្លៃខ្ពស់ ដីមានគុណភាពល្អប្រសើរដោយសារការប្រើប្រាស់សារធាតុគីមី តិចតួច។

v. លិខិតស្នាមដែលទាមទារសម្រាប់ការនាំចេញគួរត្រូវបានកាត់បន្ថយឲ្យបាននៅតិចជា អប្បបរមា ហើយប្រសិនបើអាច គួរកាត់បន្ថយមកតាមប្រតិបត្តិការច្រកចេញចូលតែមួយ ដើម្បីឲ្យក្រុមហ៊ុននាំចេញអង្ករអាចប្រកួតប្រជែងបាននៅលើទីផ្សារអន្តរជាតិ។

៤. ការចូលរួមពីដៃគូនានា

ដើម្បីបន្ធូរបន្ថយបន្ទុកចំណាយលើការអនុវត្តអនុសាសន៍ទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាអាច បង្កើនការស្វែងរកជំនួយបច្ចេកទេស និងហិរញ្ញវត្ថុបន្ថែមទៀតពីអង្គការ USAID អង្គការ AusAID ទីភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី ADB និងធនាគារពិភពលោក តាមរយៈមូលនិធិស្វែងរកទីផ្សារនាំចេញ (EMAF) សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងបណ្តា អង្គការក្រៅរដ្ឋាភិបាលនានា។

## ៧. សេចក្តីសន្និដ្ឋាន

សក្តានុពលសម្រាប់ការបង្កើនផលិតកម្មស្រូវ សក្តានុពលសម្រាប់ការលើកកំពស់គុណភាពគ្រឿង បរិក្ខារនៅក្នុងវិស័យកិនស្រូវដើម្បីឲ្យស្របតាមលក្ខខណ្ឌតម្រូវរបស់ទីផ្សារនាំចេញដែលមានសក្តានុពល និងសក្តានុពលក្នុងការទទួលបានប្រាក់កម្ចី គឺមានសម្រាប់ឲ្យទាញយកផលប្រយោជន៍។ ដូច្នេះ ទិសដៅ របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រើប្រាស់វិស័យកសិកម្ម ជាពិសេសទំនិញស្បៀងអង្ករ ជាវិស័យដ៏សំខាន់ មួយសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជានោះ នឹងអាចសម្រេចទៅបាន នៅពេលដែលភាគីពាក់ព័ន្ធទាំងអស់

ប្រមែប្រមូលនូវធនធានទាំងអស់របស់ខ្លួន និងធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធក្នុងលក្ខណៈជាប្រព័ន្ធ និងប្រកប
ដោយសាមគ្គីភាព។

បណ្ឌិត ស៊ិន ម៉េង ស្រ៊ុន
ប្រធានអនុក្រុមសិក្សាស្រាវជ្រាវសេដ្ឋកិច្ចកសិកម្ម
នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC)
អមទីស្តីការគណៈរដ្ឋមន្ត្រី